**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

លេខ: ៤០៤ ប្រក

លិខិតចូល
ថ្ងៃទី ២៣ ខែ ៤ ឆ្នាំ 2007

# ប្រកាស

## ស្តីពី

## តួនាទី ភារកិច្ច និង រចនាសម្ព័ន្ធ របស់នាយកដ្ឋាន លេខាធិការដ្ឋាន មណ្ឌលអប់រំកែប្រែ និងពន្ធនាគារខេត្ត ក្រុង ចំណុះអគ្គនាយកដ្ឋានពន្ធនាគារ ក្រសួងមហាផ្ទៃ

********

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៦/១២២ ចុះថ្ងៃទី ២២ ខែមីនា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស /រកម /០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៥០០ ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌអនុរក្សពន្ធនាគារក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១៤៨អនក្រ ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការបង្កើតអគ្គនាយកដ្ឋានពន្ធនាគារ
- បានឃើញប្រកាសលេខ ២១៧ ប្រក ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការគ្រប់គ្រងពន្ធនាគារ របស់ក្រសួងមហាផ្ទៃ
- យោងសំណើរបស់អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធនាគារ

## សំរេច

**ប្រការ ១ : អំពីភារកិច្ច និង រចនាសម្ព័ន្ធ របស់នាយកដ្ឋានប្រតិបត្តិ :**

**១- ភារកិច្ច :**

- រៀបចំសេចក្តីព្រាងច្បាប់ លិខិតបទដ្ឋាន បទបញ្ជានានា ស្តីពីការងារគ្រប់គ្រងមណ្ឌលអប់រំកែប្រែ និងពន្ធនាគារខេត្ត ក្រុង

- គ្រប់គ្រងរាល់សកម្មភាពអនុវត្តន៍ច្បាប់ ក្នុងការឃុំឃាំងពិរុទ្ធជន ទណ្ឌិត ដើម្បីធានាសុវត្ថិភាព សន្តិសុខ និងសណ្តាប់ធ្នាប់ បង្ការទប់ស្កាត់ និង ប្រឆាំងរាល់ឧបាយកលបង្ករចលាចល បំផ្លិចបំផ្លាញ ឃាដកម្ម អត្តឃាដ និង សកម្មភាពរំដោះពិរុទ្ធជន ទណ្ឌិត ដោយសហការជាមួយអង្គភាពពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន
- ចាត់វិធានការឃុំឃាំងពិរុទ្ធជន ទណ្ឌិត អោយបានត្រឹមត្រូវ ដើម្បីសម្រួលដល់ការស៊ើបអង្កេតឱ្យមានដំណើរការល្អ
- អនុវត្តដីកា សាលក្រម សាលដីការបស់តុលាការ និងព្រះរាជក្រឹត្យប្រោសប្រទាន បន្ធូរបន្ថយទោស លើកលែងទោសរបស់ព្រះមហាក្សត្រ
- បង្កើតប្រព័ន្ធទិន្នន័យស្តីពីការគ្រប់គ្រងពិរុទ្ធជន ទណ្ឌិត
- ធ្វើចំណាត់ថ្នាក់សន្តិសុខ និងឃុំឃាំងពិរុទ្ធជន ទណ្ឌិត ត្រឹមត្រូវតាមនីតិវិធីស្តីពីការគ្រប់គ្រងពន្ធនាគារ
- ដឹកនាំ ណែនាំជំនាញ ដល់មណ្ឌលអប់រំកែប្រែ និងពន្ធនាគារខេត្ត ក្រុង
- សិក្សាលក្ខណៈបច្ចេកទេសសំណង់បំរើឱ្យការឃុំឃាំងពិរុទ្ធជនទណ្ឌិត និងលើកសំណើអភិវឌ្ឍន៍ពន្ធនាគារស្របតាមបទដ្ឋានអប្បបរិមារបស់អង្គការសហប្រជាជាតិ ស្តីពីការគ្រប់គ្រងអ្នកទោស
- ធ្វើការងាររដ្ឋបាលសរុប បុគ្គលិក កសុ្តភារ ហិរញ្ញវត្ថុ របស់នាយកដ្ឋាន
- បំពេញការងារផ្សេងៗទៀត ដែលអគ្គនាយកប្រគល់អោយ ។

**២- រចនាសម្ព័ន្ធ :**

- ការិយាល័យ រដ្ឋបាល សរុប
- ការិយាល័យ តាមដានមូលដ្ឋាន
- ការិយាល័យ ទិន្នន័យ និងប័ណ្ណសារ
- ការិយាល័យ សន្តិសុខ និងអន្តរាគមន៍
- ការិយាល័យ ស៊ើបការ អប់រំ

**ប្រការ ២ : អំពីភារកិច្ច និងរចនាសម្ព័ន្ធ របស់នាយកដ្ឋានអប់រំកែប្រែ :**

**១- ភារកិច្ច :**

- រៀបចំគំរោងកម្មវិធីស្តារនីតិសម្បទា តាមរយៈការអប់រំកែប្រែផ្លូវចិត្ត និងការបណ្តុះបណ្តាលវិជ្ជាជីវៈ
- ស្រាវជ្រាវ ចងក្រងឯកសារ ទាក់ទងដល់ការអប់រំផ្លូវកាយ និងផ្លូវចិត្ត
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ បណ្តាអង្គការសង្គមស៊ីវិលជាតិ អង្គការអន្តរជាតិ ដើម្បីជួយឧបត្ថម្ភគាំទ្រដល់ការកែប្រែ និងស្តារនីតិសម្បទា ដល់អ្នកទោស
- លើកសំណើសុំបន្ធូរបន្ថយទោស និងលើកលែងទោសចំពោះទណ្ឌិតដែលអប់រំកែប្រែខ្លួនបានល្អស្របតាមច្បាប់កំណត់
- ផ្សព្វផ្សាយពត៌មានស្តីពីផែនការសកម្មភាពអប់រំកែប្រែអ្នកទោស ស្របតាមគោលការណ៍ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល
- ចាត់តាំង គ្រប់គ្រងពលកម្ម សិប្បកម្ម និងអាជីវកម្មផ្សេងៗ ដើម្បីបង្កើនចំណូល សំដៅលើកទឹកចិត្តអ្នកទោស ក្នុងការអប់រំកែប្រែខ្លួនឱ្យក្លាយជាពលរដ្ឋល្អ ពេលវិលត្រឡប់ទៅរស់នៅក្នុងសហគមន៍ជាតិវិញ
- ស្វែងរកដៃគូអភិវឌ្ឍន៍ និងទីផ្សារ ដើម្បីជំរុញអាជីវកម្មរបស់ពន្ធនាគារឱ្យមានប្រសិទ្ធភាព
- ណែនាំ អប់រំ ការពារ ព្យាបាលជំងឺ ដល់អ្នកទោសនៅគ្រប់មណ្ឌលអប់រំកែប្រែ និង ពន្ធនាគារខេត្ត ក្រុង
- លើកគំរោងស្នើសុំថវិកា ដើម្បីសាងសង់ ជួសជុលប៉ុស្តិ៍សុខភាព នៅគ្រប់មណ្ឌលអប់រំកែប្រែ និងពន្ធនាគារខេត្ត ក្រុង

- លើកគំរោងស្នើសុំថវិកា ដើម្បីសាងសង់ ជួសជុលប៉ុស្តិ៍សុខភាព នៅគ្រប់មណ្ឌលអប់រំកែប្រែ និងពន្ធនាគារខេត្ត ក្រុង
- លើកគំរោងផែនការ និង សហការជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីបណ្តុះបណ្តាលបច្ចេកទេសវេជ្ជសាស្ត្រដល់មន្ត្រីសុខាភិបាលពន្ធនាគារ
- ធ្វើកិច្ចការរដ្ឋបាល សរុប បុគ្គលិក ភស្តុភារ ហិរញ្ញវត្ថុ របស់នាយកដ្ឋាន
- បំពេញភារកិច្ចផ្សេងៗទៀត ដែលអគ្គនាយកប្រគល់ឱ្យ ។

**២- រចនាសម្ព័ន្ធ :**

- ការិយាល័យ រដ្ឋបាល សរុប
- ការិយាល័យ អប់រំ ស្តារនីតិសម្បទា
- ការិយាល័យ សុខាភិបាល
- ការិយាល័យ ផ្សព្វផ្សាយពត៌មាន
- ការិយាល័យ ផលិតកម្ម

**ប្រការ ៣ : អំពីភារកិច្ច និង រចនាសម្ព័ន្ធ របស់នាយកដ្ឋានមធ្យោបាយ :**

**១- ភារកិច្ច :**

- គ្រប់គ្រងឯកសារផ្ទាល់ខ្លួនរបស់មន្ត្រីចំណុះអគ្គនាយកដ្ឋានពន្ធនាគារ លើកសំណើជ្រើសរើស បណ្តុះបណ្តាល ហ្វឹកហ្វឺនជំនាញ តែងតាំង ដកហូតមុខតំណែង តម្លើងឋានន្តរសក្តិ ថ្នាក់ លើកសរសើរ អនុវត្តវិន័យ និងអនុវត្តគោលនយោបាយនានា តាមការកំណត់របស់ក្រសួងមហាផ្ទៃ
- លើកគំរោងផែនការ និង គ្រប់គ្រងសំភារៈ ថវិកា ប្រេងឥន្ធនៈ មធ្យោបាយដឹកបញ្ជូន របស់អគ្គនាយកដ្ឋានពន្ធនាគារ
- លើកគំរោង និងគ្រប់គ្រង ការសាងសង់ ជួសជុល និងអភិវឌ្ឍន៍មណ្ឌលអប់រំកែប្រែ ពន្ធនាគារខេត្ត ក្រុង ឱ្យបានសមស្របតាមតំរូវការចាំបាច់
- សិក្សាស្រាវជ្រាវទីតាំងភូមិសាស្ត្រពន្ធនាគារ ទំនាក់ទំនងសហការជាមួយដៃគូអភិវឌ្ឍន៍បង្កលក្ខណៈងាយស្រួលដល់ការសាងសង់ និងជួសជុលពន្ធនាគារ
- គ្រប់គ្រងរបបហូបចុក សំភារៈប្រើប្រាស់ និងការឧបត្ថម្ភ ផ្សេងៗទៀត ដល់ពិរុទ្ធជន ទណ្ឌិត ឱ្យបានត្រឹមត្រូវតាមច្បាប់ និងបទដ្ឋាននានារបស់រដ្ឋ
- បង្កើតប្រព័ន្ធទិន្នន័យស្តីពីការគ្រប់គ្រងមន្ត្រីរាជការ
- ធ្វើការងាររដ្ឋបាល សរុប របស់នាយកដ្ឋាន
- បំពេញភារកិច្ចផ្សេងៗទៀត ដែលអគ្គនាយកប្រគល់ឱ្យ ។

**២- រចនាសម្ព័ន្ធ :**

- ការិយាល័យ រដ្ឋបាល សរុប
- ការិយាល័យ បុគ្គលិក និងបណ្តុះបណ្តាល
- ការិយាល័យ ផែនការ ហិរញ្ញកិច្ច
- ការិយាល័យ ភស្តុភារ សំភារៈ បច្ចេកទេស
- ការិយាល័យ ស្ថាបនា និងថែទាំសំណង់

**ប្រការ ៤ :** នាយកដ្ឋាន និង ការិយាល័យ ដឹកនាំដោយប្រធាន ០១ រូប និងមានអនុប្រធានមួយចំនួនជាជំនួយការ ។

**ប្រការ ៥ : អំពីភារកិច្ច និងរចនាសម្ព័ន្ធ របស់លេខាធិការដ្ឋាន :**

**១- ភារកិច្ច :**

- អនុវត្តកិច្ចការរដ្ឋបាល និងគ្រប់គ្រងក្រារបស់អគ្គនាយកដ្ឋាន
- ពិនិត្យឯកសារនានារបស់អង្គភាពចំណុះអគ្គនាយកដ្ឋាន លើទំរង់រដ្ឋបាល មុនដាក់ជូនអគ្គនាយកពិនិត្យសំរេច
- តាមដាន បូកសរុប កិច្ចប្រតិបត្តិការរបស់អគ្គនាយកដ្ឋាន
- រៀបចំបដិសណ្ឋារកិច្ចចំពោះភ្ញៀវជាតិ និងអន្តរជាតិ
- រៀបចំចាត់ចែងរាល់កិច្ចការប្រជុំ និង សន្និបាតនានា របស់អគ្គនាយកដ្ឋាន
- រៀបចំកម្មវិធីការងាររបស់ថ្នាក់ដឹកនាំអគ្គនាយកដ្ឋាន
- កសាងសេចក្តីព្រាងលិខិតបទដ្ឋាននានាប់រើសំណូមពរកិច្ចការពន្ធនាគារ
- គ្រប់គ្រងឯកសាររបស់អគ្គនាយកដ្ឋាន
- បំពេញភារកិច្ចផ្សេងទៀត ដែលអគ្គនាយកប្រគល់ឱ្យ ។

**២- លេខាធិការដ្ឋានដឹកនាំដោយប្រធាន ០១ រូប មានឋានៈស្មើ នឹងអនុប្រធាននាយកដ្ឋាន**

**៣- រចនាសម្ព័ន្ធ :**

- ការិយាល័យ រដ្ឋបាល
- ការិយាល័យ សរុប
- ការិយាល័យ ក្រុមជំនួយការ

**ប្រការ ៦ : អំពីភារកិច្ច និងរចនាសម្ព័ន្ធរបស់មណ្ឌលអប់រំកែប្រែ និងពន្ធនាគារខេត្ត ក្រុង :**

**១- ភារកិច្ច ៖**

- រៀបចំទទួលឃុំឃាំងត្រឹមត្រូវតាមច្បាប់កំណត់ និងតាមនីតិវិធីពន្ធនាគារ
- ចាត់វិធានការការពារ បង្ការទប់ស្កាត់ ប្រឆាំងរាល់ឧបាយកលលួចរត់ ផែនការបំផ្លិចបំផ្លាញពន្ធនាគារ ឃាដកម្ម អត្តឃាដ និង សកម្មភាពរំដោះ ពិរុទ្ធជន ទណ្ឌិត ដោយសហការជាមួយអង្គភាពពាក់ព័ន្ធ និង អាជ្ញាធរដែនដី
- ធ្វើចំណាត់ថ្នាក់សន្តិសុខត្រឹមត្រូវតាមនីតិវិធី
- ចាត់វិធានការឃុំឃាំងពិរុទ្ធជន ទណ្ឌិត ដើម្បីសំរួលដល់ការស៊ើបអង្កេតឱ្យមានដំណើរការល្អ
- ត្រួតពិនិត្យអាគារឃុំឃាំង ប្រពន្ធ័ការពារ និងសំភារៈបច្ចេកទេស ដើម្បីធានាសន្តិសុខ សុវត្ថិភាពពន្ធនាគារ
- ចាត់តាំងកម្មវិធីអប់រំកែប្រែ ស្មារតីសីលធម៌ និងបណ្តុះបណ្តាលមុខវិជ្ជាជីវៈដល់អ្នកទោស
- ផ្គត់ផ្គង់របបហូបចុក សំភារៈប្រើប្រាស់ រៀបចំការស្នាក់នៅ និងការឧបត្ថម្ភផ្សេងទៀត តាមរបបកំណត់
- ចាត់ចែងការថែរក្សាអនាម័យ សុខភាព ការព្យាបាលជំងឺ ឬចាត់បញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យតាមស្ថានភាពជាក់ស្តែង
- ចាត់តាំងកម្មវិធីពលកម្ម សិប្បកម្ម និង អាជីវកម្មផ្សេងៗ ដើម្បីបង្កើនចំណូល សំដៅលើកទឹកចិត្តអ្នកទោស ក្នុងការកែប្រែខ្លួន ក្លាយជាពលរដ្ឋល្អពេលវិលត្រលប់ទៅរស់នៅក្នុងសហគមន៍ជាតិវិញ
- បង្កើតប្រព័ន្ធទិន្នន័យ ស្តីពីការគ្រប់គ្រងពិរុទ្ធជន ទណ្ឌិត និង ទទួលរក្សាទុកនូវទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់ពួកគេ ក្នុងរយៈពេលត្រូវជាប់ឃុំឃាំង
- រៀបចំកម្មវិធីជួបសួរសុខទុក្ខពិរុទ្ធជន ទណ្ឌិត ត្រឹមត្រូវតាមនីតិវិធី
- ចាត់វិធានការពិនិត្យឆែកឆេរចំពោះ អ្នកទោស ភ្ញៀវមកសួរសុខទុក្ខ សំភារៈនាំចូលអាគារឃុំឃាំងត្រឹមត្រូវតាមនីតិវិធីពន្ធនាគារ

- លើកសំណើសុំបន្ធូរបន្ថយទោស និងលើកលែងទោស តាមការកំណត់របស់ច្បាប់ ចំពោះទណ្ឌិតដែលបានអប់រំកែប្រែខ្លួនបានល្អ
- អនុវត្តដីកា សាលក្រម សាលដីការបស់តុលាការ និង ព្រះរាជក្រឹត្យប្រោសប្រទានបន្ធូរបន្ថយទោស លើកលែងទោសរបស់ព្រះមហាក្សត្រ
- ដឹកនាំ ណែនាំ ដាស់តឿន បំពាក់បំប៉ន ជំនាញគ្រប់គ្រងពន្ធនាគារជាប្រចាំ ដល់មន្ត្រីអនុរក្ស
- ធ្វើការងាររដ្ឋបាល សរុប បុគ្គលិក ភស្តុភារ ហិរញ្ញវត្ថុ របស់អង្គភាព
- បំពេញភារកិច្ចផ្សេងៗទៀត ដែលអគ្គនាយកប្រគល់ឱ្យ ។

**២- រចនាសម្ព័ន្ធមណ្ឌលអប់រំកែប្រែ ៖**

- ការិយាល័យ ប្រតិបត្តិ
- ការិយាល័យ អប់រំកែប្រែ
- ការិយាល័យ មធ្យោបាយ

**៣- រចនាសម្ព័ន្ធពន្ធនាគារខេត្ត ក្រុង ៖**

- ការិយាល័យ ប្រតិបត្តិ
- ការិយាល័យ អប់រំកែប្រែ
- ការិយាល័យ មធ្យោបាយ

**ប្រការ ៧ :** មណ្ឌលអប់រំកែប្រែដឹកនាំដោយប្រធានមណ្ឌល ០១ រូប មានឋានៈស្មើនឹងអនុប្រធាននាយកដ្ឋាន និងអនុប្រធានមួយចំនួនជាជំនួយការ ។ ពន្ធនាគារខេត្ត ក្រុង ដឹកនាំដោយប្រធាន ០១ រូប មានឋានៈស្មើនឹងអនុប្រធានមណ្ឌលអប់រំកែប្រែ និង មានអនុប្រធានមួយចំនួនជាជំនួយការ ។

**ប្រការ ៨ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៩ :** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធនាគារ អគ្គាធិការ នៃអគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងនគរបាល អភិបាលគ្រប់ ខេត្ត ក្រុង ប្រធាននាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រធាននាយកដ្ឋានផែនការ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង គ្រប់អង្គភាពពាក់ព័ន្ធចំណុះក្រសួងមហាផ្ទៃ ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០៧

សខ ខេង

***កន្លែងទទួល :***

- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ក្រសួងយុត្តិធម៌*
- *ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
- *រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ*
  *(ដើម្បីជូនជ្រាប)*
- *ដូចប្រការ៩*
  *(ដើម្បីអនុវត្ត)*
- *ឯកសារ កាលប្បវត្តិ*

GDpt RH4